**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើកវេទិកាពិភាក្សា “លើកកម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាង”

សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវតំណាងក្រសួង ស្ថាប័ន*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាបើកវេទិកាពិភាក្សា **“លើកកម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាង”** ដ៏មានសារៈសំខាន់នាពេលនេះ។

ឆ្លៀតក្នុងឱកាសដ៏មហាវិសេសវិសាលនេះ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អំពីស្ថានភាពនៃការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ទាក់ទងនឹងភាពងាយរងគ្រោះរបស់ក្មេងស្រី និងយុវវ័យជានារី និងអ្វីដែលស្ថាប័នរដ្ឋ ឯកជន និងសង្គមស៊ីវិលត្រូវចូលរួមបង្ការ និងដោះស្រាយភាពប្រឈមរបស់ក្មេងស្រី និងយុវវ័យជានារី នៅពេលដែលយើងទាំងអស់គ្នាចូលរួមក្នុងការសម្រេចគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការឈានឆ្ពោះទៅរកការបញ្ចប់នូវជំងឺអេដស៍ នៅឆ្នាំ២០២៥ដែលជាការគំរាមកំហែងចំពោះសុខភាពសាធារណៈ។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះ មូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍ (AHF) ដែលបានផ្តួចផ្តើមគំនិតរៀបចំវេទិកាលើកកម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាងនៅប្រទេសកម្ពុជា។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការចូលរួមរបស់ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងអង្គការ UNWOMEN ផងដែរ។

ការផ្តួចផ្តើមគំនិតនៃយុទ្ធនាការនេះគឺ ជាការចូលរួមចំណែកក្នុងការកាត់បន្ថយនូវភាពងាយរងគ្រោះសង្គម សេដ្ឋកិច្ច និងសុខភាពរបស់ស្ត្រីវ័យក្មេង និងក្មេងស្រីចំនួន៦១%នៃយុវវ័យ៤លាននាក់លើសកលលោកដែលមានអាយុ១៥ដល់២៤ឆ្នាំ បច្ចុប្បន្នកំពុងផ្ទុកមេរោគអេដស៍។

យុទ្ធនាការនេះសំដៅផ្តល់សិទ្ធិអំណាចដល់ក្មេងស្រីរាប់លាននាក់ នៅទូទាំងពិភពលោកដែលភាគច្រើនប្រឈមនឹងភាពក្រីក្រ អំពើហិង្សាប្រឆាំងនឹងភេទ និងការរំលោភបំពានលើសិទ្ធិផ្លូវភេទ និងការបន្តពូជ ដើម្បីឱ្យក្មេងស្រី និងយុវវ័យជានារីបានទៅសាលារៀន ធ្វើការជ្រើសរើស និងគ្រប់គ្រងសុខភាពរាងកាយ និងអារម្មណ៍កាន់តែប្រសើរឡើង។

ក្នុងរយៈពេល១៥ឆ្នាំកន្លងមក សហគមន៍ពិភពលោកក៏ដូចជាប្រទេសកម្ពុជាដែរ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវិតរបស់ក្មេងស្រីក្នុងវ័យកុមារភាព។ ក្នុងឆ្នាំ២០១៥ កុមារីដែលស្ថិតក្នុងវ័យ១០ឆ្នាំដំបូងនៃជីវិត ទំនងជាចុះឈ្មោះចូលរៀននៅបឋមសិក្សា ទទួលការចាក់វ៉ាក់សាំងសំខាន់ៗ ហើយងាយទទួលរងនូវបញ្ហាសុខភាព និងអាហារូបត្ថម្ភតិចជាងមនុស្សជំនាន់មុន លើកលែងតែជំនាន់ប៉ុល ពត។

ទោះយ៉ាងណាក៏ដោយ ក៏មានការវិនិយោគមិនគ្រប់គ្រាន់ក្នុងការដោះស្រាយនូវបញ្ហាប្រឈមរបស់ក្មេងស្រី នៅពេលពួកគេចូលក្នុងវ័យលើសពី១០ឆ្នាំនៃជីវិតរបស់ពួកគេ។ បញ្ហានេះរួមមានការទទួលបានការអប់រំដែលមានគុណភាពនៅ កម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ការជៀសវាងនូវអាពាហ៍ពិពាហ៍កុមារ ការទទួលបានព័ត៌មាននិងសេវាកម្មទាក់ទងនឹងសុខភាពមនុស្សពេញវ័យ និងសុខភាពបន្តពូជ និងការពារខ្លួនពួកគេពីការមានផ្ទៃពោះដែលមិនចង់បាន ការឆ្លងជំងឺកាមរោគ និងអំពើហិង្សាប្រឆាំងនឹងភេទ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

យោងតាមលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤បានបង្ហាញថា ៖

- សមាមាត្រស្ត្រី និងក្មេងស្រីដែលមានអាយុ១៥ឆ្នាំឡើងទៅដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូបច្ចុប្បន្ន ឬអតីតក្នុងរយៈពេល១២ខែចុងក្រោយមាន៣០,៨%។
- សមាមាត្រស្ត្រី និងក្មេងស្រីដែលមានអាយុ១៥ឆ្នាំឡើងទៅដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយពីដៃគូបច្ចុប្បន្ន ឬអតីតក្នុងរយៈពេល១២ខែចុងក្រោយមាន១៧,៩%។
- សមាមាត្រស្ត្រី និងក្មេងស្រីដែលមានអាយុ១៥ឆ្នាំឡើងទៅដែលធ្លាប់ទទួលរងនូវអំពើហិង្សាផ្លូវចិត្តពីដៃគូបច្ចុប្បន្ន ឬអតីតក្នុងរយៈពេល១២ខែចុងក្រោយមាន២៤,៨%។
- សមាមាត្រស្ត្រី និងក្មេងស្រីដែលមានអាយុ១៥ឆ្នាំឡើងទៅដែលធ្លាប់ទទួលរងនូវអំពើហិង្សាផ្លូវភេទពីដៃគូបច្ចុប្បន្ន ឬអតីតក្នុងរយៈពេល១២ខែចុងក្រោយមាន៥,៥%។

ទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់ផ្ទុកមេរោគអេដស៍ លើមនុស្សពេញវ័យ (អាយុ១៥ដល់៤៩ឆ្នាំ) ដោយធ្វើឱ្យធ្លាក់ចុះពី ១,៧%ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ០,៨% ក្នុងឆ្នាំ២០១០ និងមកដល់ ០,៥%ក្នុងឆ្នាំ២០១៩។ ចាប់តាំងពីឆ្នាំ២០១០មក ការឆ្លងថ្មីនៃមេរោគ

អេដស៍បានថយចុះ៦២% ដែលនៅក្នុងនោះមានករណីឆ្លងថ្មីប្រមាណ ៨៨០នាក់ក្នុងឆ្នាំ២០១៨។ ចាប់តាំងពីឆ្នាំ២០១០មក ការស្លាប់ដែលទាក់ទងនឹងជំងឺអេដស៍បានថយចុះ ៤៨% មកនៅប្រមាណ ១.៣០០នាក់ក្នុងឆ្នាំ២០១៨។

ចំពោះទិន្នន័យដែលបញ្ជាក់ពីវឌ្ឍនភាព និងជោគជ័យនេះ យើងក៏មិនមានព័ត៌មានជាក់លាក់ និងលម្អិតដែលបញ្ជាក់ពីភាពងាយរងគ្រោះរបស់ក្មេងស្រី និងយុវវ័យជានារីឡើយ។ យើងមិនដឹងថា ក្នុងចំណោមអ្នកដែលបាត់បង់ជីវិតប្រមាណ១០០.០០០នាក់ដោយសារជំងឺអេដស៍ ចាប់ពីទសវត្សរ៍ឆ្នាំ១៩៩០ និងក្នុងចំណោមប្រជាជនប្រមាណ៧៣.០០០ដែលកំពុងតែរស់នៅជាមួយមេរោគអេដស៍នោះ មានយុវនារីប៉ុន្មាននាក់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូបច្ចុប្បន្ន ឬអតីតដៃគូនោះដែរទេ។

ក្រៅពីសម្ពាធដោយផ្ទាល់ នៅមានសម្ពាធដោយប្រយោលដែលធ្វើឱ្យក្មេងស្រី និងស្ត្រីមានការប្រឈមនឹងមេរោគអេដស៍។ ឧទាហរណ៍ បច្ចុប្បន្ននេះមានស្ត្រីប្រមាណជាង៣ម៉ឺននាក់ដែលកំពុងធ្វើការនៅក្នុងគ្រឹះស្ថានកម្សាន្តសប្បាយដែលអត្រាផ្ទុកមេរោគអេដស៍មាន២,៣% ក្នុងឆ្នាំ២០១៦។ ប៉ុន្តែស្ត្រីឯករាជ្យមានអត្រាផ្ទុកមេរោគអេដស៍រហូតដល់១១,៨៥%។ កម្រិតប្រើប្រាស់ស្រោមអនាម័យជាមួយភ្ញៀវមាន៨៦% ប៉ុន្តែជាមួយដៃគូទៀងទាត់មានត្រឹមតែ២៧%ប៉ុណ្ណោះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

រាជរដ្ឋាភិបាលបានចាត់ទុកការលុបបំបាត់អំពើហិង្សាលើស្ត្រីជា កម្មវិធីអាទិភាពដែលគ្រប់ស្ថាប័នរដ្ឋ ឯកជន និងសង្គមស៊ីវិលត្រូវតែចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ លុបបំបាត់ និងផ្តល់សេវាជួយជនរងគ្រោះឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ឆ្ពោះទៅសម្រេចឱ្យបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០១៦-២០៣០ នៅក្នុងគោលដៅទី៥ ៖ សម្រេចឱ្យមានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប។

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៩-២០២៣ អាជ្ញាជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រកាន់យកគោលការណ៍មួយចំនួនដែលគាំទ្រដល់យុទ្ធនាការលើកកម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាង ដែលមានជាអាទិ៍ អភិក្រមដែលផ្តោតលើប្រជាជនជាចម្បង (People Centered Approach) សមភាពយេនឌ័រ ទំនោរផ្លូវភេទ អត្តសញ្ញាណ និងការស្តែងអារម្មណ៍យេនឌ័រ (Sexual Orientation, Gender Identity and Expression, SOGIE)។

យុទ្ធសាស្ត្រទី២ នៃផែនការយុទ្ធសាស្ត្រជាតិលើកទី៥ អំពាវនាវឱ្យមានការសហការជិតស្និទ្ធរវាងអ្នកពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទាក់ទងគ្នារវាងមេរោគអេដស៍ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជនិងសិទ្ធិ និងការគ្របដណ្តប់សុខភាពសកល (sexual and reproductive health and rights, SRHR & universal health coverage, UHC)។

ដើម្បីដោះស្រាយកត្តាកំណត់សង្គម សេដ្ឋកិច្ច និងសុខភាពពីភាពងាយរងគ្រោះ (Social economic and health determinants) នឹងមេរោគអេដស៍ និងជំងឺអេដស៍ និងធានាបាននូវការឆ្លើយតបប្រកបដោយចីរភាព និងការអភិវឌ្ឍនានា តាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលចង្អុលទិសឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងពាក់ព័ន្ធអនុវត្តនូវវិធានការ៦ចំណុចរួមមាន ៖ ១) ការផ្តល់ថវិកាដល់អាជ្ញាធរមូលដ្ឋានដើម្បីគាំទ្រការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ២) ការគាំពារសង្គមសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ ៣) ការធានាកញ្ចប់ថវិកាសម្រាប់ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដើម្បីអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៤) ការគាំទ្រអង្គការសង្គមស៊ីវិល ៥) ការធានាលំហថវិកាសម្រាប់ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និង៦) ការបង្កើនប្រសិទ្ធភាពរបស់ក្រសួងសុខាភិបាលដោយពង្រឹងធនធានមនុស្ស លទ្ធកម្ម និងប្រព័ន្ធព័ត៌មាន។ វិធានការដែលមានក្នុង សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ២១៣ សជណ.សស សំដៅកាត់បន្ថយភាពប្រឈមទៅនឹងមេរោគអេដស៍ដោយផ្ទាល់ និងដោយប្រយោលដូចជា កត្តាកំណត់សង្គម និងសេដ្ឋកិច្ចផងដែរ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមគាំទ្រចំពោះក្រសួងសុខាភិបាលដែលបានចេញនូវគោលការណ៍អនុវត្តវិធីលេបថ្នាំបង្ការជាមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ( Pre Exposures Prophylaxis, PrEP) កាលពីខែមីនា ឆ្នាំ២០១៩កន្លងទៅ និងការចាប់ផ្តើមឱ្យអនុវត្តគោលការណ៍នេះ នៅរាជធានីភ្នំពេញ និងខេត្តក្រុងមួយចំនួន។ នេះជាឧទាហរណ៍មួយទៀតនៃការកាត់បន្ថយភាពប្រឈមទៅនឹងមេរោគអេដស៍ផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ដើម្បីជាការចូលរួមក្នុងវេទិកាពិភាក្សា "លើកកម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាង"នេះ ខ្ញុំសូមឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងស្ថាប័នរដ្ឋ ឯកជន និងសង្គមស៊ីវិលចូលរួមកម្លាំងគ្នាប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ និងជួយដោះស្រាយកត្តាកំណត់សង្គម សេដ្ឋកិច្ច និងសុខភាព ធ្វើយ៉ាងណាឱ្យក្មេងស្រី និងយុវនារី ដឹកនាំជីវិតឱ្យចាកផុតពីភាពរងគ្រោះ និងអំពើហិង្សាគ្រប់រូបភាព មានចំណេះដឹង មានសមត្ថភាព មានជឿជាក់លើខ្លួនឯង ថែទាំសុខភាពឱ្យបានល្អ ខិតខំកសាងខ្លួន និងកសាងគ្រួសារ រស់នៅក្នុងភាពសុខដុមរុងរឿងគ្រប់ៗគ្នា។

ជាទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ មូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍ (AHF) និងអ្នកដែលចូលរួមរៀបចំវេទិកាពិភាក្សានេះឱ្យប្រព្រឹត្តទៅដោយរលូន និងជោគជ័យ។ ខ្ញុំក៏សូមជូនពរគណៈអធិបតី ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកវេទិកាពិភាក្សា **"លើកកម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាង"** ចាប់ពីពេលនេះតទៅ។

សូមអរគុណ។